Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣

## លទ្ធផលវេទិកា នៅខេត្តក្រចេះ
## "កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក្រោមកិច្ចសហការជាមួយបណ្ដាអង្គការ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរៀបចំវេទិកាមួយ ស្ដីអំពី **"កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា (FOREDS)"** នៅ **ខេត្តក្រចេះ** កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ តំណាងគ.ជ.បខេត្ត អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធប្រមាណ **៩២នាក់**។

វេទិកានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធបានលើកឡើង និងជជែកពីបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ គោលនយោបាយដែលបានពិភាក្សាចែកជូនដល់អ្នកចូលរួម និងបញ្ជូនអនុសាសន៍ទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធក្នុងការដោះស្រាយ។

| **អនុសាសន៍ពី វេទិកា FOREDS នៅខេត្តក្រចេះ (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣)** |
|---|
| **១. ការជ្រើសរើស និងការពង្រឹងសមត្ថភាពមន្ត្រីបោះឆ្នោតនៅថ្នាក់ឃុំ និងថ្នាក់ការិយាល័យបោះឆ្នោត**<br>**បញ្ហា**<br>ការជ្រើសរើសមន្ត្រីធ្វើការងាររៀបចំការបោះឆ្នោតពីមុនគឺ ជ្រើសរើសតែបក្សពួក អ្នកមានសមត្ថភាពពុំមានឱកាសចូលរួមទេ។<br>**អនុសាសន៍**<br>• ស្នើសុំឱ្យមានសមាសភាពក្នុងគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភាចូលរួមផង ជៀសវាងការមានមន្ទិលសង្ស័យពីគ្នាទៅវិញទៅមក។<br>• មន្ត្រីបំរើការងារក្នុងការិយាល័យបោះឆ្នោតពីមុនពុំមានសមត្ថភាព ស្នើសុំឲ្យជ្រើសរើសមន្ត្រីមានសមត្ថភាព និងបណ្ដុះបណ្ដាលបន្ថែមនៅពេលក្រោយ ព្រមទាំងបង្កលក្ខណៈងាយស្រួលចំពោះការរកឈ្មោះអ្នកទៅបោះឆ្នោត។<br>• អ្នកដែលប្រព្រឹត្តិខុសច្បាប់បោះឆ្នោត ត្រូវតែមានការដាក់ទោសទណ្ឌ និងបញ្ឈប់កុំឱ្យបំរើការងារនេះបន្តទៀត។<br>• ស្នើសុំឱ្យមន្ត្រី CEC មានការទទួលខុសត្រូវក្នុងតួនាទីរបស់ខ្លួន (ទាក់ទងនឹងការចែកប័ណ្ណព័ត៌មាន មិនត្រូវ |

ទីស្នាក់ការកណ្ដាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

| |
|---|
| ប្រគល់ឱ្យអាជ្ញាធរ ភូមិ ឃុំ) ដាច់តែឯងទេ ត្រូវសុំការសហការណ៍ ។<br>• ស្នើសុំជ្រើសរើសមន្ត្រីចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ជ្រើសរើសផ្សេងក្រៅពីស្មៀនឃុំ។ |
| **២. ការទប់ស្កាត់ និងបង្ការអំពើហិង្សាពេលបោះឆ្នោត**<br>• អាជ្ញាធរ ភ្នាក់ងារគណបក្សនយោបាយត្រូវគោរពច្បាប់បោះឆ្នោតឲ្យបានពេញលេញ ហើយគណៈកម្មការរៀបចំការបោះឆ្នោត ត្រូវដាក់ពិន័យទៅតាមច្បាប់បោះឆ្នោត<br>• សន្តិសុខទទួលខុសត្រូវក្នុងការិយាល័យបោះឆ្នោតត្រូវតែជាមនុស្សដែលរស់នៅក្នុងមូលដ្ឋាន នៃការិយាល័យបោះឆ្នោត<br>• សន្តិសុខគ្រប់រូបត្រូវបានបំពាក់បំប៉នពីច្បាប់បោះឆ្នោត តួនាទីក្នុងកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សំរាប់ការិយាល័យ និងអ្នកបោះឆ្នោត<br>• បណ្តុះបណ្តាលច្បាប់បោះឆ្នោតដល់អ្នកសង្កេតការណ៍ មន្ត្រីគណបក្សនយោយបាយ ការអនុវត្តន៍ក្រមសីលធម៌សម្រាប់ការបោះឆ្នោត។<br>• សន្តិសុខការិយាល័យបោះឆ្នោតត្រូវទំនាក់ទំនងល្អ (ផ្តល់ព័ត៌មាន) ប្រតិបត្តិល្អជាមួយមន្ត្រីបោះឆ្នោត សកម្មទទួលយករាល់ពាក្យណ្តឹងផ្សេងៗដើម្បីដាក់ជូនប្រធានការិយាល័យបោះឆ្នោត និងចាត់វិធានការដោះស្រាយ។ |
| **៣. ដំណោះស្រាយបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោត**<br>• ស្នើសុំឲ្យមានស្ថាប័នថ្មីក្នុងការដោះស្រាយបណ្តឹងទាក់ទងការបោះឆ្នោត<br>• ស្នើសុំឲ្យនាយកដ្ឋាននីតិកម្មនៃស្ថាប័នរបស់គ.ជ.ប ធ្វើការផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋអំពីដំណើរការនៃការដាក់ និងទទួលពាក្យបណ្តឹងទាក់ទងទៅនឹងការបោះឆ្នោត។<br>• ពង្រឹងសមត្ថភាពគណៈកម្មការ CEC និង PEC ក្នុងការដោះស្រាយបណ្តឹងឲ្យមានប្រសិទ្ធិភាព ។<br>• ពន្យារពេលដាក់ពាក្យបណ្តឹងត្រឹមម៉ោង ៥ល្ងាច ២ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត |
| **៤. សេរីភាពក្នុងការបញ្ចេញមតិ និងប្រមូលផ្តុំ**<br>**<u>បញ្ហា</u>**<br>• ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានមិនមានសេរីភាពគ្រប់គ្រាន់ ដោយសារមេភូមិច្រើនតែគាំទ្រគណបក្សកាន់អំណាចមិនឲ្យបញ្ចេញមតិអ្វីក្រៅពីគណបក្សកាន់អំណាច<br>• ប្រជាពលរដ្ឋគ្មានសិទ្ធិគ្រប់គ្រាន់ក្នុងការជួបជាមួយតំណាងរាស្ត្រមិនកាន់អំណាច ដោយមានអាជ្ញាធរភូមិឃុំហាមឃាត់<br>• ច្បាប់នៃការបញ្ចេញមតិមាន ប៉ុន្តែបុគ្គលមួយចំនួននៅតែបំពាន<br>**<u>អនុសាសន៍</u>**<br>• មេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ត្រូវគាំទ្រឲ្យមានសេរីភាពគ្រប់គ្រាន់ក្នុងការបញ្ចេញមតិ ឬចូលរួមក្រៅពីគណបក្សរបស់ខ្លួន។<br>• ផ្តល់ឱកាសជូនគ្រប់គណបក្សនយោបាយក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងរបស់ឯកជនឲ្យបានស្មើៗគ្នា។ |

- សូមឲ្យសេរីភាពនៃការបញ្ចេញមតិមានព្រំដែន ដោយជៀសវាងការវាយប្រហារខុសការពិត ពាក្យសំដីត្រូវប្រកបដោយក្រមសីលធម៌ កុំប្រើពាក្យអសុរស ត្រូវផ្អែកលើច្បាប់ កុំសន្យា ហើយមិនធ្វើដោយកេងចំណេញពីនយោបាយ។
- ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋទៅលើការធ្វើបាតុកម្ម ត្រូវគោរពតាមច្បាប់ដែលបានចែង ដូចជាការស្នើសុំធ្វើបាតុកម្ម ត្រូវផ្តល់ព័ត៌មានទៅក្រសួងមានសមត្ថកិច្ច អំពីទីកន្លែង ចំនួនអ្នកចូលរួម និងមានតំណាងដឹកនាំមួយច្បាស់លាស់ ដូចនេះវាគួរតែអនុវត្តទាំងសមត្ថកិច្ច និងបាតុករ។

**៥. ហិរញ្ញវត្ថុគណបក្សនយោបាយ**

គាំទ្រឲ្យមានច្បាប់ស្តីពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

**អានុសាសន៍**

- កំណត់ចំនួនអតិបរមា នៃការចំណាយក្នុងការឃោសនាបោះឆ្នោត
- គណបក្សនយោបាយ និងបេក្ខជនត្រូវបង្ហាញរបាយការណ៍ចំណាយដល់សាធារណៈជន និងសមាជិកគណបក្សនយោបាយ
- គ.ជ.ប/ ក្រុមឯករាជ្យតាមដាន និងត្រួតពិនិត្យរបាយការណ៍ចំណាយរបស់គណបក្សនយោបាយ
- រដ្ឋត្រូវតែបដិភាគថវិកា និងការផ្សព្វផ្សាយដល់គណបក្សនយោបាយពេលយុទ្ធនាការឃោសនាបោះឆ្នោត

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ៖*

*១-លោក **សួន យុត្យា** / មន្ត្រីតស៊ូមតិ និងច្បាប់ខុមហ្វ្រែល (០៩៧-៥៩-៨៧-២៦៥)*

*បេសកម្ម ៖* បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ **ទី១**/ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក **ទី២**/ ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។